**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៦៩០ សហវ.ប្រក

# ប្រកាស

## ស្ដីពី

## ការអនុវត្តអាករលើតម្លៃបន្ថែម
## ចំពោះការផលិតនិងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ស្ដីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្ដីពីអាករលើតម្លៃបន្ថែមលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច ÷

**ប្រការ ១ .~ គោលបំណង**

ប្រកាសនេះមានគោលបំណងសម្រួលយន្តការអាករលើតម្លៃបន្ថែមលើការផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីជួយសម្រួលនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដើម្បីអនុវត្តឱ្យមានសង្គតិភាពនិងអនុលោមភាពតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

**ប្រការ ២ .~ វិសាលភាពអនុវត្ត**

ការដាក់ចេញនូវយន្តការអនុគ្រោះ ក្នុងការអនុវត្តអាករលើតម្លៃបន្ថែម ដូចមានចែងក្នុងប្រកាសនេះ អនុវត្តចំពោះតែការផលិតទឹកស្អាតដើម្បីផ្គត់ផ្គង់ជូនប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ។ ប្រកាសនេះមិនអនុវត្តចំពោះការផលិតទឹកបរិសុទ្ធសម្រាប់ទទួលទានគ្រប់ប្រភេទ។

**ប្រការ ៣ .~ ការកំណត់អាករលើតម្លៃបន្ថែម**

អាករលើតម្លៃបន្ថែម អនុវត្តចំពោះការផលិតនិងផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ ត្រូវបានកំណត់ដូចតទៅ ÷

១. ការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់ ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់មិនជាប់អាករ

២. ការផ្គត់ផ្គង់ទំនិញ ឬសេវាក្រៅពីទឹកស្អាតដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០%។

**ប្រការ ៤ .~ ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ផលិតនិងចែកចាយទឹកស្អាត ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃ មាត្រា ២៩ ដល់មាត្រា ៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៥ .~**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ